# ការសំភាសន៍របស់យាយ អ៊ឹម

កៈ អ្នកដែរសំភាសន៍ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ យាយ អ៊ឹម

**<u>ការសង្ខេបប្រវត្តិរបស់លោកយាយ អ៊ឹម</u>**

លោកយាយ អ៊ឹម មានអាយុ66 ឆ្នាំ នៅក្នុងឆ្នាំ2018។លោកយាយ អ៊ឹម មានភេទស្រី។លោកយាយ អ៊ឹម មានទីលំនៅបច្ចុប្បន្ននៅភូមិ បាល្លាំងថ្មី ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ជូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ចា៎!បាន

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី19 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិ បាល្លាំងថ្មី

ខៈ នៅបាល្លាំងថ្មីនៅក្រោយវត្តយើងនឹង

កៈ ក្រោយវត្តបាល្លាំងថ្មីនឹង ឃុំរអា ស្រុកកំពង់សៀម ខេត្តកំពង់ចាម បាទអ៊ុំចឹងសំរាប់អ៊ុំមានឈ្មោះពេញ នឹងឈ្មោះអីគេដែរទៅអ៊ុំ?

ខៈ ខ្ញុំឈ្មោះនាង អ៊ឹម ប្ដីឈ្មោះ ដុល

កៈ ប៉ុន្តែមានឈ្មោះហៅក្រៅដែរទេអ៊ុំ?

ខៈ អត់មានទេនឹង មានឈ្មោះតែដុល អឺមនឹងក្រៅអត់មានសោះ

កៈ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងទៀតទេអ៊ុំ?

ខៈ អត់មានទេ

កៈ ចុះអ៊ុំសព្វថ្ងៃអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំអាយុ66ឆ្នាំហើយនឹង

កៈ ចុះអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរទៅអ៊ុំ?

ខៈ អត់ឆ្នាំទេនឹង

កៈ បាទអ៊ុំ ចុះឆ្នាំខ្មែរអ៊ុំមានឈ្មោះអីគេដែរអ៊ុំឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ុំ?

ខៈ ខ្ញុំឆ្នាំរោង

កៈ ចឹងអ៊ុំកើតនៅឆ្នាំរោងណអ៊ុំ?

ខៈ ខ្ញុំអាយុស្គរតាហ៊ុន សែននឹង

កៈ អូ៎!បាទចឹងអ៊ុំកើតនៅឆ្នាំ1952អ៊ុំ?

ខៈ ចឹងហើយចាំ!

កៈ ចុះអ៊ុំកើតនៅណាដែរអ៊ុំនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីដែរអ៊ុំ?

ខៈ ខ្ញុំកើតនៅស្រុកបាល្លាំង វាលខ្សាច់នឹងតែម្តងនឹង ស្រុកកំពង់សៀម នឹងខេត្តកំពង់ចាមនឹងតែម្តងនឹង

កៈ ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំមានបងប្អូនចំនួន5នាក់ មានប្រុស4នាក់ នឹងស្រីមានតែខ្ញុំមួយនឹងទេ

កៈ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំជាកូនបងគេបង្អស់នឹង

កះ  ចុះបងប្អូនរបស់អ៊ុំតើអ៊ុំអាចប្រាប់ឈ្មោះពួកគាត់បានដែរទេអ៊ុំ?

ខះ  ខ្ញុំអាចប្រាប់បានដែរតើ!

កះ  មានឈ្មោះអីគេខ្លះដែរទៅអ៊ុំ?

ខះ  បន្ទាប់ខ្ញុំនឹងឈ្មោះរិណា , ហើយមកទៀតឈ្មោះ រុណា, ហើយបានឈ្មោះ ហី , បន្ទាប់មកបានឈ្មោះ ផល មានតែ5នាក់ទេនឹង

កះ  ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅក្មេងៗជាមួយគាត់ហាស?

ខះ  នៅក្មេងតូចៗនឹងខ្ញុំលេងតែលាក់កន្សែង លេងបុកចាប

កះ  ប៉ុន្តែមានលេងបិទពួនអីដែរតើហីអ៊ុំ?

ខះ  លេងពួនអីនឹងចឹងទៅណាស់ ជាមួយម៉ារបស់ខ្ញុំនឹងគាត់ចាស់ ចឹងគាត់ថាហែងទៅលេងបិទពួនឡូ ឡានឹងប្រយ័ត្នអញ់វៃហាស ចឹងអត់ហ៊ានលេងជាមួយគាត់ទេ ម៉ារបស់ខ្ញុំនឹងគាត់អាយុប៉ែតជាងហើយនឹង ម៉ាគៀនខ្ញុំនឹង

កះ
អ្ហ៎!បាទអ៊ុំចុះអ៊ុំចូលចិត្តលេងអីគេជាមួយបងប្អូនរបស់អ៊ុំកាលពីអ៊ុំនៅក្មេងៗដែរចឹងហាសអ៊ុំ?

ខះ  ចូលចិត្តលេងខាងនេះនឹងដូចថាខាងធ្វើអាសុខឡាបុងៗហោសដុតក្តាម ដុតបង្កង់ម៉េចហោស

កះ  អ្ហ៎!បាទអ៊ុំ?

ខះ  ហើយនឹងអូសត្រឡាច

កះ  អ្ហ៎!អង្គុយជាប់សសរហើយអោបត្រឡាចនឹងហោសអ៊ុំ?

ខះ  អោបទៅដួលរេលលើគ្នាហើយសើចទៅណាស់

កះ  ធ្លាប់លេងឡឹកបាយឡរីមួយលេងការអីជាមួយគ្នាដែរទេអ៊ុំ?

ខះ  ការក៏លេងដែរអ្នកខ្លះទៅបេះផ្កាយកមកធ្វើចឹងទៅណាស់ដាក់ផ្កាពេញនឹងចឹងទៅ ហើយធ្វើការកូន ក្រមុំនឹងកូនកំលោះធ្វើថ្មីមគ្នា ហើយមានលោកមានអីចឹង

កៈ លោកនឹងយកមនុស្សយើងធម្មតាទេ?

ខៈ ធ្វើធម្មតានឹង

កៈ អូ!ចឹងទេហោសអ៊ុំ?

ខៈ យកភួយក្រហមនឹងមកធ្វើជាលោកទៅណាស់ពពានាធ្វើលោកទៅណាស់

កៈ អ៊ុំចេះមានវិធីទៀត?

ខៈ ចេះតែធ្វើៗទៅនឹង ហើយនាំគ្នាទៅសំពះលោកទៅណាស់

កៈ អូ!បាទអ៊ុំចឹងហោស?

ខៈ ពីមុនចឹងមែននឹងណាស់

កៈ ចុះដូចជាបងប្អូនរបស់អ៊ុំឥឡូវនឹងគាត់នៅណាដែរអ៊ុំ?

ខៈ បងប្អូនរបស់ខ្ញុំនឹងហោសនៅល្អាងមួយ នៅប្រប្រកមួយ នៅប្រខុងមួយ
នៅបាល្លាំងពីរនាក់ នៅបាល្លាំងពីរនឹងពីណាគេខ្លះទៅចឹង

កៈ ចឹងនៅបាល្លាំងពីរនាក់ណាអ៊ុំ?

ខៈ នឹងនៅបានល្លាំងពីរនៅតែខ្ញុំ នឹងតាផលទេនឹងប្អូនពៅរបស់ខ្ញុំនឹងមានឈ្មោះផល

កៈ អូ!បាទអ៊ុំចុះពួកគាត់ធ្វើអីគេខ្លះដែរទៅអ៊ុំឥឡូវនឹង?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លាប់បាត់ហើយនឹង
គាត់អនិច្ចកម្មបាត់ហើយនឹងគាត់ឈ្មោះតាស្រេង យាយគីម គាត់ឈឺជំនាន់អាពត

កៈ ប៉ុន្តែបងប្អូនរបស់អ៊ុំហោសគាត់ធ្វើអីគេដែរសព្វថ្ងៃនឹងហោស?

ខៈ បងប្អូនរបស់ខ្ញុំហោស មានតាផល តាហី តារុណ

កៈ ប៉ុន្តែគាត់ធ្វើអីគេដែរទៅអ៊ុំ?

ខៈ គាត់មានធ្វើអីដឹកតែគោនឹងរាល់ថ្ងៃធ្វើស្រែបន្តិចបន្តួចស្រែបានតែបន្តិចនឹង
បានស្រូវ10ថាំនឹង

កៈ អូ!ចឹងហោសអ៊ុំ?

ខ៖ ស៊ីមិនគ្រាន់ទេនឹង

ក៖ ឪពុកម្តាយរបស់អ៊ុំ តើអ៊ុំមានដឹងថាគាត់កើតនៅឆ្នាំអីទេអ៊ុំ?

ខ៖ ខ្ញុំមិនចាំសោះនឹង

ក៖ ចុះគាត់អាយុប៉ុន្មានក៏អ៊ុំមិនចាំដែរ?

ខ៖ បើពុករបស់ខ្ញុំនឹងគាត់ស្លាប់អាយុ70ឆ្នាំ

ក៖ ចុះគាត់ស្លាប់ប៉ុន្មានឆ្នាំដែរហើយអ៊ុំ?

ខ៖ កាត់ស្លាប់បាត់យូរដែរហើយនឹងតាំងពីជំនាន់ពលពតនឹងមក

ក៖ ចឹងមានន័យថាយូរដែរហើយណាអ៊ុំ?

ខ៖ តាំងពីជំនាន់ឆ្នាំ1975នឹងមក ខ្ញុំចាំតែឆ្នាំ1975នឹងពុករបស់ខ្ញុំបានស្លាប់ គាត់ស្លាប់នឹងឆ្នាំ1977-1978 ហើយនឹងចុះបើដាច់ឆ្នាំ1979នឹងមកហើយនឹង

ក៖ ចឹងមានន័យថាគាត់ស្លាប់នឹងអស់ប្រហែលជាជាង40ឆ្នាំហើយនឹងអ៊ុំ?

ខ៖
ពុករបស់ខ្ញុំនឹងគាត់ស្លាប់នឹងអត់បាយដែរនឹងស្គមៗហើមខ្លួនចឹងទៅគេបង្អត់បាយគាត់នឹង

ក៖ ចឹងគេបង្អត់បាយដែរណាអ៊ុំ?

ខ៖ នឹងហើយពេលចឹងគេយកចេកទៅអោយគាត់ស៊ីនឹងគាត់ថាមិនស៊ីទេខ្លាចអាពតវៃ

ក៖ ចឹងហោសអ៊ុំ?

ខ៖ យកនុំកន្ទួកអោយគាត់ស៊ីគាត់ថាខ្លាចអាពតវៃ
ហើយមើលគោៗនឹងក៏បានដួលស្លាប់បាត់ទៅនឹង កំសត់ណាស់ជាមួយឪពុករបស់ខ្ញុំនឹង

ក៖ ចុះឪពុករបស់អ៊ុំនឹងគាត់កើតនៅណាដែរអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំនឹងកើតនៅពង្រ នៅឯទួលប្រាសាទ

ក៖ ចុះម្តាយរបស់អ៊ុំវិញគាត់កើតនៅណាដែរអ៊ុំ?

ខ៖ ម៉ែកើតនៅនឹងដែរ

កៈ ចឹងគាត់កើតនៅនឹងតែម្តងហោសអ៊ុំ?

ខៈ ចា៎!ស្រុកកំណើតគាត់នៅនឹង ខ្ញុំក៏ស្រុកកំណើតនៅនឹងដែរនឹង

កៈ ចុះឪពុករបស់អ៊ុំនឹងកាលពីគាត់នៅរស់តើគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ ឡើងត្នោតដឹកគោ ធ្វើស្រែ

កៈ អូ៎!គាត់ឡើងត្នោតហោសអ៊ុំ?

ខៈ នឹងហើយគាត់ធ្វើចឹងនឹង រកត្រី

កៈ គាត់រកត្រីអីវិញអ៊ុំ?

ខៈ គាត់ច្រើនតែឡើងត្នោតនឹងគាត់មិនសូវជារកត្រីទេនឹង

កៈ ឡើងត្នោតលក្ខណៈយកទឹកត្នោតយកអីនឹងហោសអ៊ុំ?

ខៈ ស្កររំងាស់លេងទឹកមួយថ្ងៃពីរខ្នះត្នោតនឹង

កៈ ប្រើទឹកច្រើនហាសណអ៊ុំ?

ខៈ ខ្ញុំជាអ្នកដុតភ្លើងហើយជួយរឹកជួយអីចឹងទៅណាស់

កៈ ចឹងមានន័យថាឪពុករបស់អ៊ុំគាត់ចេះកូរស្កត្នោតនឹង

ខៈ គាត់កូរស្កនឹង

កៈ ចឹងអ៊ុំក៏ចេះធ្វើដែរ?

ខៈ ខ្ញុំចេះធ្វើដែរនឹង

កៈ ចឹងមានន័យថាឪពុករបស់អ៊ុំបានបង្រៀនអោយចេះទៅ?

ខៈ នឹងហើយគាត់បង្រៀនអោយចេះនឹង

កៈ ចុះឪពុករបស់អ៊ុំនឹងគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខៈ ឪពុករបស់ខ្ញុំនឹងពីណាក៏គេថាស្លូតដែរថាតាស្រេងស្លូតណាស់
គាត់មិនចេះអីទេគាត់ស្លូតណាស់ តារបស់ខ្ញុំនឹងមិនដែរទៅវៃនរណាមួយដំបងទេ

ក៖  ចុះម្ដាយរបស់អ៊ុំវិញគាត់ជាមនុស្សបែបណាវិញអ៊ុំ?

ខ៖  ម៉ែរបស់ខ្ញុំនឹងក៏កាត់ស្លូតដែរនឹង ម៉ែរបស់ខ្ញុំនឹងចាំតែស្ទួដាច់អីចាំតែទៅលក់ស្ទួនឹងទៅ

ក៖  អូ៎!ចឹងទេអ៊ុំ?

ខ៖
គាត់បានត្រីបានអីចឹងគាត់ទៅលក់ទៅណាស់និយាយពីសត្វធាតុវិញគាត់មិនដែរចិញ្ចឹមផង
នឹង ពុកខ្ញុំវិញតែមាន់មួយនឹងមិនហ៊ានអាករផងនឹង

ក៖  អូ៎!ចឹងហោសអ៊ុំ?

ខ៖  គាត់ថាខ្លាចបាប

ក៖  ចុះម្ដាយរបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំ?

ខ៖  ម៉ែរបស់ខ្ញុំនឹងគាត់ស្លូតនឹងនៅតែស្រុកនៅតែផ្ទះនឹងលក់ដូរៗ

ក៖  អូ៎!បាទអ៊ុំចឹង?

ខ៖  គាត់នៅលក់ស្ទួអីចឹងទៅ នឹងលក់ស្រូវអីចឹងស្រូវចឹងបាន3ដឹកនឹងមួយឆ្នាំៗហោស
មួយឆ្នាំនឹងស៊ីរួចមួយឆ្នាំ

ក៖  ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយឪពុកម្ដាយរបស់អ៊ុំទេ
ធ្លាប់ធ្វើអីជាមួយគាត់ចឹងហាសអ៊ុំ?

ខ៖  មិនលឺខ្ញុំនិយាយលេងតែឡឹកបាយឡ លេងតែលាក់កន្សែងអីនឹង

ក៖  ជាមួយឪពុកម្ដាយហាសអ៊ុំ?

ខ៖  អូ៎!កាលពីក្រមុំហោស

ក៖  បាទនៅជាមួយឪពុកម្ដាយនឹងអ៊ុំចូលចិត្តធ្វើអីគេជាមួយឪពុកម្ដាយដែរអ៊ុំ?

ខ៖  ដឹកតែគោនឹងមានគោ5-6ក្បាលនឹងស្អីក៏មិននឹកឃើញដែរដឹកតែគោទេ
អត់មានទៅសប្បាយណា ជាមួយប្រុសឈ្មោលអត់មានទេ

ក៖  ចុះម្ដាយរបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តកាលពីគាត់នៅក្មេងទៅអ៊ុំដែរទេ?

ខ៖ គាត់ថាកាលពីជំនាន់ពីគាត់នៅក្មេងនឹងគាត់មានបងសក់ហើយនឹងមានពួកម៉ាក់គាត់គាត់ដើរលេង
ចឹងទៅគាត់សប្បាយដែរទៅណាមានក្មេងៗក្រមុំៗនឹងគេជូនគ្នាទៅចឹងណាស់

ក៖ បាទចឹងហោសអ៊ុំ?

ខ៖
គាត់មិនអោយដើរតែម្នាក់ឯងទេនឹងគាត់ខ្លាចមានមនុស្សប្រុសណាខូវខិលអីចាប់កូនចៅរបស់យើង នឹងណាស់

ក៖ បាទចឹងអ៊ុំ?

ខ៖
គាត់ជូនទៅហើយនឹងទៅមើលល្ខោនក៏គាត់ជូនទៅដែរនៅពីក្រោយខ្នងម៉ែខ្ញុំនឹងអោយប្រវត្តិល្អ ម៉ែថាអើយនេះយើងហាសអោយប្រវត្តិល្អ កុំអោយមានប្រវត្តិអាក្រក់ណាស់

ក៖ បាទគាត់និយាយត្រូវអ៊ុំ

ខ៖
អោយល្អចុះនឹងហើយទៅណាមកណាគាត់ជូនទៅហើយទៅកំពង់ចាមក៏គាត់ជូនទៅដែរចឹងហាស ទៅណាក៏ទៅដែរម៉ែខ្ញុំនឹង ខ្ញុំក៏តាមគាត់ដែរនឹង

ក៖ អូ!គាត់អោយអ៊ុំតាមគាត់រហូត?

ខ៖ តាមរហូតនឹង ខ្ញុំដើរតាមម៉ែរបស់ខ្ញុំរហូតនឹង

ក៖ ចុះឪពុករបស់អ៊ុំនឹងគាត់ជាមនុស្សបែបណាដែរអ៊ុំ?

ខ៖ ឪពុករបស់ខ្ញុំនឹងគាត់ឡើងត្នោតនឹងគាត់រកត្រីបន្តិចបន្តួចនឹង

ក៖ ប៉ុន្តែគាត់មានធ្លាប់ប្រាប់ថាប្រវត្តិរបស់គាត់នឹងនៅក្មេងយ៉ាងម៉េចទេអ៊ុំ?

ខ៖ គាត់នៅក្មេងនឹងគាត់មើលក្របីនឹង

ក៖ គាត់មើលក្របីហោសអ៊ុំ?

ខ៖ ចា៎!នឹងហើយ

កៈ អូ៎!បាទអ៊ុំចុះចឹង?

ខៈ ខ្ញុំនឹងគាត់ច្រើនតែមើលតែគោ នឹងក្របីគាត់ធ្វើអីទេនឹង ជំនាន់ពីដើមនឹងមើលតែក្របីនឹងមើលគោនឹង

កៈ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះពួកគាត់ដែរអត់អ៊ុំ?

ខៈ ខ្ញុំស្គាល់តើនឹង

កៈ គាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ តារបស់ខ្ញុំនឹងតាឈ្មោះតាភី នឹងយាយឈ្មោះយាយគួរ

កៈ ចុះយាយតាខាងម្ដាយវិញ?

ខៈ យាយតាខាងម្ដាយរបស់ខ្ញុំនឹងឈ្មោះយាយកៀន តាសៅ

កៈ ប៉ុន្ដែអ៊ុំមានដឹងថាគាត់កើតនៅណាទេអ៊ុំយាយតាខាងម្ដាយ នឹងខាងឪពុកហាស?

ខៈ យាយតាគាត់ប្រាប់ថាគាត់កើតនៅខ្នងក្រពើ

កៈ នៅខ្នងក្រពើហោស?

ខៈ មិនដឹងថានៅណាទេខ្នងក្រពើនឹងលឺថានៅត្រើយម្ខាងនឹង

កៈ អូ៎!នៅត្រើយម្ខាងនឹងហោសអ៊ុំ?

ខៈ ចា៎!នៅណុងឯង

កៈ ចុះនឹងចុះយាយតាខាងឪពុកវិញអ៊ុំ?

ខៈ ណុងយាយតាខាងឪពុកនឹងនៅខ្នងក្រពើនឹងណាស់

កៈ ចុះយាយតាខាងម្ដាយគាត់កើតនៅណាដែរអ៊ុំ?

ខៈ យាយតាខាងម្ដាយគាត់កើតនៅស្រុកបាល្លាំងនឹងណាស់

កៈ អូ៎!បាទចឹងគាត់នៅនឹងទេ?

ខៈ ហ៊ោ!បើតាសៅនឹងគាត់មកពីស្រុកចិនហាស តាសៅខ្ញុំនឹងចិនគាត់និយាយមិនច្បាស់ទេ

កៈ អ៎ូ!គាត់ចិនហោស ចឹងមានន័យថាដល់យាយនឹងក៏គាត់កាត់ចិនខ្លះដែរនឹង?

ខៈ កាត់ដែរនឹងបានកូនមកវាទ្រង់រាងចិនៗនឹង

កៈ រាងចិនហោសអ៊ុំ?

ខៈ ចិនណាមួយៗឡើងខ្មៅដូចធ្យូងនឹងវាស៊ីប្រហុកទៅវាមិនខ្មៅទៅនោះចិនហោស

កៈ គាត់ចិនហោសអ៊ុំ?

ខៈ នឹងចិនហោសទៅ

កៈ ចឹងគ្រួសាររបស់អ៊ុំនឹងមកនៅនឹងយូរនៅអ៊ុំ?

ខៈ
គ្រួសាររបស់ខ្ញុំតារបស់ខ្ញុំមកយកខ្ញុំក្រោយនឹងវាជិត15ឆ្នាំហើយនឹងមកនៅនឹងហោសអ៊ុំ?

ខៈ មកនៅនឹងស្រុកកំណើតគាត់មកពាម ព្រៃកពោ ព្រៃកពោនឹងឪពុកទេ
ប៉ុន្តែស្រុកកំណើតដែរគាត់ កើតតែម្តងនឹងនៅពាម

កៈ ចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ អត់មានសោះគ្មាននរណាគេផ្តល់លុយអោយមួយរយមួយសេននឹង

កៈ ប៉ុន្តែនៅថៃ នឹងនៅវៀតណាមអីក៏អត់មានដែរ?

ខៈ អត់មានទេចឹងបានខ្ញុំធ្លាក់ខ្លួនក្រនឹងណាស់
រាល់ថ្ងៃខ្ញុំមានតែលុយ2000រៀលនៅក្នុងហោប៉ាវទេនឹង
តាហើយតាខ្ញុំបែបវៃគ្នាហើយបើតាឯងធ្វើបាបខ្ញុំចឹង
គាត់បានលុយតិចតួចនឹងគាត់យកទៅចាក់
ថាកុំចាក់តាបានលុយតិចតួចនឹងយកលុយទៅទិញអង្ករស៊ីហើយនឹង

កៈ អ៎ូ!យ៉ាប់?

ខៈ ហ៎ា!ត្រូវនិយាយប្រវត្តិអោយអស់ចឹង

កៈ បាទអ៊ុំត្រូវហើយនិយាយអោយអស់

ខ៖  ហ៉ា!តាថ្ងៃនេះអត់មានលុយទៅទិញអង្ករស៊ីទេតា កុំយកលុយខ្ញុំទៅចាក់ឆ្នោតហាស

ក៖  ទៅទិញអង្ករសិន?

ខ៖  ទិញអង្ករសិនប្រយ័ត្នតែអត់អង្ករស៊ីនឹងដាច់ពោះស្លាប់ហើយនឹង

ក៖  អូ៎!បាទអ៊ុំ?

ខ៖  ខ្ញុំនិយាយាចឹងតែម្ដងនឹងហាស

ក៖  ចុះស្វាមីរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរទៅអ៊ុំ?

ខ៖  គាត់ឈ្មោះតារ៉ែន

ក៖  ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយតាដែរទេ?

ខ៖  គាត់ការនឹងគាត់ការយូរឆ្នាំហើយណាសុខ គាត់តើបតែយកប្រហែលជា10ឆ្នាំនេះនឹង

ក៖  ចឹងប្រហែលជា10ឆ្នាំនឹងទេ?

ខ៖ នឹងហើយយកប្ដីក្រោយ

ក៖
ចុះនៅពេលដែរអ៊ុំរៀបអាពាហ៍ជាមួយតាគិតថាអ៊ុំជាអ្នករៀបដោយចិត្តឯងរឺមួយក៏ម្ដាយឪពុកជាអ្នក រៀបអោយដែរអ៊ុំ?

ខ៖  ទេម្ដាយឪពុករបស់ខ្ញុំជាអ្នករៀបអោយ មានគ្រូអាចារ្យអីត្រឹមត្រូវ មានបាច់ស្លាអីនឹងដែរ

ក៖  ចុះពេលដែររៀបអាពាហ៍នឹងពេលដែរតាចូលស្ដីដណ្ដឹងអ៊ុំនឹងមានជាជំនូនទេអ៊ុំ?

ខ៖  មានដែរនឹង

ក៖  ដូចជាប៉ុន្មានដែរអ៊ុំអាចប្រាប់ខ្ញុំបានទេ?

ខ៖  មានជំនូនប៉ុន្មាន10-20ម៉ឺននឹង គ្រាន់តែគាត់ជូនយើងទិញសំលអីមកសែននឹង

ក៖  អ៊ុំងាចប្រាប់ខ្ញុំបានទេថាហេតុអីបានតាស្រលាញ់អ៊ុំ
ហើយស្រលាញ់នៅពេលណានិយាយពីប្រវត្តិ ស្នេហាបានទេអ៊ុំ?

ខ៖ ប្រវត្តិស្នេហាចាំមើលខ្ញុំនិយាយខ្ញុំនិយាយអោយអស់ចឹងមិនចេះលាក់ទេនឹង
គាត់នឹងគាត់ឈឺដល់ពេលចឹងគាត់មករកខ្ញុំអោយរកថ្នាំផឹក
ដល់ពេលដែរផឹកនឹងគាត់ផឹកថ្នាំខ្មែរនឹងវាជាទៅ ក៏យកខ្ញុំធ្វើជាប្រពន្ធចឹងទៅ

ក៖ ចឹងមានន័យថាពេលដែរអ៊ុំឈឺអ៊ុំទៅរកគាត់ចឹងមានន័យថាគាត់គ្រូថ្នាំមែនអ៊ុំ?

ខ៖ ខ្ញុំអ្នកគ្រូតើ!

ក៖ អ្ហូ!ចឹងទេខ្ញុំស្មានតែអ៊ុំអ្នកឈឺ?

ខ៖ គាត់អ្នកគ្រូថ្នាំតានឹងអ្នកឈឺទេ ដល់ពេលដែរបំរើៗទៅក៏ត្រូវគ្នាទៅណាស់

ក៖ ចឹងទេហោសអ៊ុំប្រវត្តិអ៊ុំ?

ខ៖
នឹងហើយខ្ញុំដេញអោយគាត់ទៅស្រុកគាត់មិនទៅទេចឹងក៏នៅជាមួយដល់ឥឡូវនឹងទៅណា
ស់

ក៖ ចុះអ៊ុំមានចេះអានរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអ៊ុំ?

ខ៖ អក្សរខ្មែរចេះតែអក្សរណា ម មួយទេ បើរៀននៅថ្នាក់ទី1នឹង

ក៖ អក្សរ ណា ម នឹងអីគេដែរអ៊ុំ?

ខ៖ អក្សរ ណា ម នឹងក ខ គ ឃ ង អីនឹងណាស់

ក៖ អ្ហូ!ចឹងទេហោសអ៊ុំ?

ខ៖ ខ្ញុំចេះខ្លះដែរនឹង

ក៖ ប៉ុន្តែអ៊ុំរៀននៅណាដែរអ៊ុំ?

ខ៖ ខ្ញុំរៀននៅសាលាថ្មគោលនឹង

ក៖ នៅថ្មគោលនឹង ចុះសាលាឈ្មោះអីគេដែរអ៊ុំ?

ខ៖ សាលានឹងគេដាក់ឈ្មោះសាលាបឋមសិក្សាថ្មគោលនឹងតែម្តងនឹង

ក៖ ចុះជុំធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខ៖  មនុស្សខ្ញុំគ្រាន់តែឃើញប្រុសមិនបានផងនឹង ឃើញតែប្រុសនឹងខ្លាចនឹង

ក៖  ម៉េចចឹងអ៊ុំ?

ខ៖  មិនដឹងខ្ញុំគ្រាន់តែឃើញប្រុសនឹងខ្ញុំទូលក្រម៉ាចេះ វាអៀននឹង

ក៖  ប៉ុន្តែអ៊ុំមានមិត្តភក្តិទេ?

ខ៖  យើងមិត្តភក្តិស្រីៗនឹងក៏យើងវាអៀនដែរនឹង ឃើញស្រីៗនឹងក៏ទូលដែរមិនអោយឃើញមិខគេទេ

ក៖  បិទចឹងតែម្តងអ៊ុំ?

ខ៖  បិទឃើញតែគ្រាប់ភ្នែកមួយនឹងទេវាអៀនប្រុសៗនឹងណាស់ ហើយគេហៅអោយទៅប្រលងចំរៀង នឹងទៅបានម្តងនឹងគេដែរ

ក៖ អ៊ុំធ្លាប់ទៅប្រលងចំរៀងដែរ?

ខ៖ នឹងហើយដល់ពេលដែរទៅដល់ទល់មុខប្រុសនឹងក៏មកប្រាប់ម៉ែថាម៉ែអើយអាគាត់នោះទ្រង់ឈ្លើយ ណាស់អោយខ្ញុំទល់មុខគ្នា ហើយខ្ញុំប្រាប់ថាខ្ញុំមិនច្រៀងទេខ្ញុំខ្មាស់ណាស់

ក៖  ចឹងហោសអ៊ុំ?

ខ៖  រំលងបាន4-5ថ្ងៃនឹងមកហៅទៅទៀត ប៉ុន្តែខ្ញុំមិនទៅទេ

ក៖  ទៅប្រលងចំរៀងទៀត?

ខ៖  ប្រលងចំរៀងនឹង

ក៖  ប្រលងនៅណាវិញអ៊ុំប្រលងនៅសាលានឹងមែនអ៊ុំ?

ខ៖  អត់ទេប្រលងនៅសាលមហោសស្រពកំពង់ចាមនឹង

ក៖  អូ៎!ចឹងទេហោសអ៊ុំ?

ខ៖  ខ្ញុំអៀនចឹងខ្ញុំមិនទៅទេ

ក៖  ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរទេអ៊ុំ?

ខ៖ អូយ!ខ្ញុំមិនបានរៀនបារាំងសោះខ្ញុំបានរៀនតែខ្មែរនឹង

ក៖ ចឹងអ៊ុំមិនចេះភាសាបារាំងទេ?

ខ៖ មិនចេះទេនឹង

ក៖
ចុះអ៊ុំតាំងពីក្មេងហាសរហូតមកដល់ពេលនេះនឹងគិតថាការងារអីគេខ្លះដែរអ៊ុំធ្លាប់ធ្វើដែរនឹងអ៊ុំ?

ខ៖ ការងាររបស់ខ្ញុំនឹងដាច់ភ្លាមនឹងមកទូលអូសឡើងចង់ត្រពែកក្បាលនឹង ឥឡូវនឹងក៏ខ្ញុំនៅតែរកអូស លក់ដែរនឹងមួយថ្ងៃបាន5000-6000រៀលនឹង

ក៖ ចឹងអ៊ុំលក់អូសរហូតនឹង?

ខ៖ អូសក្រៀមយើងនឹងកាប់ទូលយកទៅលក់ទៅណាស់

ក៖ ប៉ុន្តែយើងទៅរកមកពីណាវិញអ៊ុំ?

ខ៖ យើងទៅរកនៅមាត់បឹងនឹង

ក៖ ចឹងមានន័យថាព្រឹកមិញនឹងអ៊ុំទៅតាំងព្រឹកហើយណអ៊ុំ?

ខ៖ នឹងហើយទៅតាំងពីព្រឹកនឹង

ក៖ អូ៎!ចឹងអ៊ុំលក់អូស ចឹងអ៊ុំគិតថាអ៊ុំធ្លាប់មានអាជីវកម្មលក់ដូរអីទេអ៊ុំ?

ខ៖ លក់អីច្រើនដែរ

ក៖ មិនមែនលក់តែអូសនឹងទេ?

ខ៖ ទេពីក្រមុំនឹងខ្ញុំជួញស្លាគេមកលក់ស្លាស្រះគេនឹង10ផែននឹងដាក់ស្រះម្តងនឹង ហើយចំណេញមួយ ដើងនឹងបាន7ពាន់ទៅ8ពាន់ចឹងដែរនឹង

ក៖ ចឹងចំណេញតិចដែរអ៊ុំ?

ខ៖ នឹងហើយទូលមួយល្អីប៉ុននេះៗទៅផ្សារ ហើយជិះរបកក្រហមដែរគេធាក់នឹងណាស់

ក៖ បាទល្អដែរអ៊ុំ?

ខ៖  ទៅលក់ទៅហើយដាំទ្រពទៅពេលបានផលក៏យកទៅលក់ទៅណាស់ មានត្រឡាច ទ្រព នឹងម្ទេសក្តូឆ្មានឹងទៅលក់ទៅណាស់

ក៖  ចឹងអ៊ុំធ្វើច្រើនដែរអ៊ុំ?

ខ៖  ហើយនឹងធ្វើស្រែធ្វើចំការនឹងដឹកគោនឹង រួចស្រុកកំណើតរបស់ខ្ញុំនឹងនៅនឹងទេ

ក៖  ចុះអ៊ុំធ្លាប់ដែរចិញ្ចឹមសត្វទេអ៊ុំ?

ខ៖  ចិញ្ចឹមតែគោនឹង ហើយនឹងចិញ្ចឹមមាន់2-3នឹង

ក៖  អូ៎!បាទអ៊ុំ?

ខ៖  ហើយដូចដែរខ្ញុំនិយាយចឹងខ្មោចឪពុកខ្ញុំនឹងមិនហ៊ានសំលាប់មាន់ទេនឹង គាត់ថាខ្លាចបាប បើឃ្លានមាន់អីនឹងគាត់ថាកូនឯងទៅទិញមាន់ស្លាប់នៅកំពង់ចាមទៅ

ក៖  អូ៎!ចឹងអ៊ុំ?

ខ៖  មិនបាច់ទៅធ្វើទេពុកមិនហ៊ានធ្វើទេនឹង

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរយ៉ាងម៉េចដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះហាស មានការផ្លាស់ប្តូរអីគេដែរ?

ខ៖ ខ្វតល្វះនឹងខ្ញុំធ្លាក់ខ្លួនពេលដែរវាចាស់ទៅណាស់គ្មានសូវបានទៅរកអីប៉ុន្មានទេទៅរកតែអូសមួយមុខ ទេនឹងរកថ្នាំនឹង

ក៖  ចង៉ឺអ៊ុំរកថ្នាំដែរទៅ?

ខ៖  នឹងហើយដូចថាគេរកថ្នាំកូនខ្ចីចឹងទៅ ក្រម៉ង់ថ្នាំក្រពះអីនឹងតៅរកអោយគេទៅណាស់

ក៖  ចឹងហោសអ៊ុំថ្នាំទាល់តែគេក្រម៉ង់បានអ៊ុំទៅរក?

ខ៖  នឹងហើយ គ្មានរកអីទេមានតែប៉ុណ្ណឹងទេនឹង ចុះបើយើងសុំសិល្ប៍ហើយបើយើងទៅសំលាប់សត្វបាប

ក៖  ចឹងហោសត្រូវអ៊ុំ

ខ៖ បើយើងសំលាប់ជីវិតគេយើងបាបហើយនឹង

ក៖ បាទនឹងហើយអ៊ុំ?

ខ៖ តាំងពីនឹងមកចងចាំរហូតដុចគេក្តេចត្រចៀកចឹងហាស សំលាប់ជីវិតគេបាប
ដល់ពេលចឹងក៏ទៅកាប់ អូសទៅណាស់ នឹងរកថ្នាំទៅចងចាំតែប៉ុណ្ណឹងស្អីក៏មិនរកដែរនឹង

ក៖ ចឹងហោសអ៊ុំ?

ខ៖ ប្អូនរបស់ខ្ញុំហៅទៅជីកដំឡូងនឹងក៏ខ្ញុំមិនទៅដែរនឹង
ខ្លាចជីកប៉ះម្រឹមព្រះខ្លាចស្លាប់គេបាបទៀត

ក៖ ចុះម្ហូបអីដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខ៖ ម្ហូបនឹងខ្ញុំចូលចិត្តខាងមិនដូចយាយទេ ចូលចិត្តខាងត្រីញាំុនឹង ហើយនឹងស្ងោជ្រក់
នឹងខត្រី ចូលចិត្តតែប៉ុណ្ណឹងឯង

ក៖ ចឹងអ៊ុំចូលចិត្ត?

ខ៖ នឹងស្លកក្ទូរអីនឹងស្លកក្ទូរត្នោតនឹង

ក៖ ចុះអ៊ុំចេះច្រៀងទេ?

ខ៖ បើនិយាយពីច្រៀងនឹងខ្ញុំមានអីខ្ញុំចេះតែច្រៀងកើតហើយនឹង

ក៖ ចឹងអ៊ុំចូលចិត្តច្រៀងបុរាណ រឺមួយច្រៀងសម័យដែរអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តតែច្រៀងបុរាណនឹង

ក៖ ចុះជុំគិតថាបទចំរៀងអីដែរអ៊ុំគិតថាអ៊ុំចងចាំដែរទៅចំណាងជើងបទចំរៀងហាសអ៊ុំ?

ខ៖ ដល់ពេលឥឡូវនឹងខ្ញុំចូលសិល្បហើយចង់ភ្លេចដែរនឹង

ក៖ អូ!មិនអីទេអ៊ុំ ប៉ុន្តែអ៊ុំចូលចិត្តស្តាប់បទចំរៀងទេអ៊ុំ?

ខ៖ បើដូចឥឡូវនឹងខ្ញុំចូលចិត្តបទចង្កេះរាងរាវ ដូចទេពកញ្ញាអីចឹងទៅណាស់
ខ្លាចប្រុសមុខខ្មូរមិនហ៊ាន ចូលច្រៀង
សង្ហាបានតែរូបរាងមិនហ៊ានចូលច្រៀងនឹងអួតថាក្លាហាននឹង ចឹងៗទៅណាស់

កៈ ចុះអ៊ុំគិតថាអ៊ុំចូលចិត្តមើលល្ខោន យីកេអីដែរតើហីអ៊ុំ?

ខៈ រឿងយីកេល្ខោននឹងខ្ញុំចូលចិត្តទៅណាស់ ទាល់តែស្កូវក្បាលនឹងក៏ខ្ញុំទៅដែរនឹង ថ្ងៃមុននឹងទៅមើលគេបានតែបន្តិចនឹងក៏មកវិញទៅនឹង

កៈ ចុះអ៊ុំគិតថាមាននរណាគេនៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំ?

ខៈ
និយាយពីភ្លេងនឹងមានតែតារបស់ខ្ញុំនឹងគាត់កូតទ្រនឹងប៉ុន្តែគាត់កូតទ្របានតែបន្តិចនឹងទេ គាត់ឈប់ទ្រកូតទៀតនឹងឥឡូវនឹង

កៈ បាទអ៊ុំបាទ?

ខៈ តារបស់ខ្ញុំនឹងបើទ្រនឹងប្រាកដមែន
គាត់ហាសគាត់ទៅភ្នំដល់ពេលចឹងទៅគាត់យកទ្រទៅលាក់នឹង
ទឹកហូរដល់ពេលដែរគេដើរជាន់ទៅក៏បាក់ដងទៅណាស់

កៈ ចឹងហោសអ៊ុំ?

ខៈ
នឹងហើយដល់ពេលមកវិញនឹងហីយាយគេដើរជាន់ដងទ្រហើយលែងបានទ្រកូតហើយនឹង រូចទ្រនឹងវា40$មួយនឹងទ្រ ហើយតានឹងទ្រកូតពិរោះណាស់

កៈ ចុះជុំគិតថាផ្ទះរបស់អ៊ុំមានលក្ខណះបែបណាដែរអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះ?

ខៈ ផ្ទះរបស់ខ្ញុំនឹងកូនខ្ទមតូចទេសួរតែប្អូនថ្លៃខ្ញុំនឹងដឹងហើយ ខ្ទមសសរប៉ុនៗកដៃនឹង

កៈ ចឹងណអ៊ុំ?

ខៈ ប៉ុន្តែប្តីរបស់ខ្ញុំពីមុននឹងគាត់អារតែឈើទេ

កៈ អ៊ូ!បាទអ៊ុំ ចុះដល់ពេលឥឡូវនឹងផ្ទះយ៉ាងម៉េចដែរអ៊ុំ?

ខៈ ឥឡូវនឹងផ្ទះរាងគ្រាន់បើផ្ទះបានប្រកដែក បានសសររាងត្រើសៗដែរនឹង

កៈ ចុះនរណាគេជាអ្នកធ្វើផ្ទះមួយនឹងដែរអ៊ុំអ៊ុំជួលគេរឺមួយក៏អ៊ុំធ្វើដោយខ្លួនឯងនឹង?

ខៈ អត់ទេផ្ទះនឹងខ្ញុំទិញពីគេទេនឹង

កៈ  អូ៎!អ៊ុំទិញតហោសអ៊ុំ?

ខៈ  មានអ្នកស្រុកគេមេត្តា ករុណាគេអាណិតខ្ញុំគេជួយអោយលុយមកទិញនឹង

កៈ  ចឹងទេហោអ៊ុំ?

ខៈ  រួចក៏ស្តីអោយគេជួយសែងទៅណាស់

កៈ  បាទចឹងអ៊ុំ?

ខៈ  នៅទៅប៉ុន្តែផ្ទះណុងវាទាប

កៈ  ចុះគិតថាពេលណាដែរអ៊ុំគិតថាលំបាកជាងគេនៅក្នុងជីវិតរបស់អ៊ុំដែរ?

ខៈ  រឿងពិបាកនឹងខ្ញុំថាហូរទឹកភ្នែកហើយនឹង

កៈ  ពិបាកខ្លាំងហោសអ៊ុំ?

ខៈ
ជួនកាលដូចអ្វីដែរខ្ញុំនិយាយចឹងពេលដែរដាច់អាពតមកនឹងមានអង្ករតែមួយកំប៉ុងទេមានគ្នា6នាក់ នឹងបបរនេនោង បបរសណ្តែក អីនឹងជាមួយនេនោងទៅនឹង
ហើយនាំគ្នាហុតទៅនឹងដាក់ប្រហុកតែមួយនឹង

កៈ  អូ៎!ចឹងហោសអ៊ុំ?

ខៈ  ប៊ីចេងក៏គ្មាន ប្រហុកក៏គ្មានដែរ
បបរមួយឆ្នាំប៉ុននេះហុតទៅប៉ះចំនេនោងរវឹងនឹងចាក់ចោលទៅក៏
ដេកអត់បាយមួយយប់ទៅ

កៈ  ជំនាន់ពលពតនឹងហោសអ៊ុំ?

ខៈ  ជំនាន់ពលពតដាច់មកនឹង

កៈ  ចុះកាលពីជំនាន់ពលពតនឹងគេអោយអ៊ុំធ្វើអីគេខ្លះដែរទៅអ៊ុំ?

ខៈ  ហាន់ដើមចេកនឹងមួយថ្ងៃពីរដើមអីចឹង

កៈ  ហាន់ធ្វើអីគេដែរទៅបង?

ខ៖ ហាន់បុកអោយជ្រូកស៊ីនឹង ហើយជ្រូកគេនឹងធំជាងនឹងទៀត ដល់ពេលដៃរស្លាប់ជ្រូកគេមកតិចតៀន យើង ថាយើងថៃជ្រូកមិនជិនដល់នឹង

ក៖ ជ្រូកមានច្រើនមែនអ៊ុំ?

ខ៖ អោយខ្ញុំទៅថៃយ៉ាងម៉េចបើជ្រូកមានតែ160ជ្រូកណុង ហើយមានគ្នាតែ3នាក់នឹងអាពតគេមក តិចតៀនយើងនឹង

ក៖ អ្ហូ!ចឹងហោសអ៊ុំ?

ខ៖ ប៉ុន្តែគេមិនសំលាប់យើងទេដូចថាថ្ងៃនេះមកថាអោយពីព្រោះតែស្លាប់ជ្រូកអស់2ទៅហើយនឹង ហើយខ្ញុំថាអើយធ្វើម៉េចទេបើស៊ីវាគ្រប់គ្រាន់នឹង

ក៖ ចុះម៉េចទៅចឹងអ៊ុំ?

ខ៖ មានកណ្តុះពីរល្អីនឹងមានជ្រូក160ក្បាល ហើយហាន់ដើមចេកនឹងបរទេះទៅក្នុងព្រៃហើយរទេះនឹង ផ្លុកយើងនឹងចុះយើងស្រីជាអ្នកបរទេះនឹង

ក៖ ចឹងហោសអ៊ុំ?

ខ៖ ហើយបរទេះនឹងវាកាន់ខ្សែនឹងចង់រកផ្លុកនឹងខ្ញុំភ័យរឿងបរទេះនឹងមានតែពីរនាក់ទេដៃរទៅនឹង

ក៖ ប៉ុន្តែពេលណុងដូចជាដាច់នៅ?

ខ៖ ពេលណុងដាច់ហើយៗៗនឹង

ក៖ ប៉ុន្តែពេលណុងជំនាន់ពលពតនឹងគេអោយអ៊ុំទៅណាខ្លះដែរទៅអ៊ុំ?

ខ៖ ខ្ញុំស្រុកកំណើតនៅនឹងប៉ុន្តែគេមានគ្នាន4នាក់គេថាចេះថៃហាថៃខ្ញុំជំលាសថៃឯងតែ3ថ្ងៃទេនឹង ថាថៃឯងទៅនៅទួលប្រសាទទៅណាស់

ក៖ ចុះអ៊ុំធ្វើម៉េចទៅ?

ខ៖ គេដេញខ្ញុំទៅទួលប្រសាទនឹង បើចែងងនៅនឹងស្ពីទេបន្ទាយនេះ

ក៖ នៅក្រោយបន្ទាយយើងនឹងហោស?

ខ៖ ចាំ!ថាគ្រាប់នឹងបន្តក់មកចំចែងងហើយនឹងចឹងចែងងចេះតែទៅទៅនឹង ដល់ពេលដែរចេញពីទួល ប្រសាទនឹងទៅដល់ល្អាក

ក៖ ដើររហូតហោសអ៊ុំ?

ខ៖ នឹងហើយនៅល្អាកចឹងទៅនៅក្រូចសើចនឹង ថាដើរនៅគ្រប់កន្លែងនឹងគ្រាន់តែរណ្តៅមាន9នឹងជីក ហាត់ណាស់

ក៖ ជីកធ្វើអីគេដែរអ៊ុំ?

ខ៖ ជីករណ្តៅនឹងដើម្បីជ្រកនឹងមាន9រណ្តៅនឹង ចាជីក9រណ្តៅនឹងជ្រក់

ក៖ បាទអ៊ុំបាទនឹង?

ខ៖ ដល់ពេលហើយដើរពីល្អាក ទៅដល់ក្រូចសើចនឹងហើមជើងនឹង

ក៖ ចុះម៉េចចឹងអ៊ុំ?

ខ៖ កដើរអត់មានស្បែកជើងទេនឹង

ក៖ ដើរហាលក្តៅនឹងតែម្តងហោសអ៊ុំ

ខ៖ ចាំ!ដើរហាលថ្ងៃនឹងហា ដើរទៅឡើងហើមជើងនឹងជើងនឹងឡើងក្រហាយ លើងរបូតស្បែក

ក៖ បាទអ៊ុំនឹងហើយ?

ខ៖ លើងកំសត់ណាស់

ក៖ រហូតដល់ឥឡូវនឹងអ៊ុំនៅតែលំបាក?

ខ៖ លំបាកណាស់គ្មានកូនចៅណាទៅក្រៅប្រទេសទេនឹង បើវាទៅក្រៅទៅថាវាអោយលុយយើង10-20$ សំរាប់ចាយយើងតែគ្មានសោះនឹង

ក៖ បាទចឹងអ៊ុំ?

ខ៖
នៅរាល់ថ្ងៃនឹងមានកូនប្រុសមួយប៉ុន្តែភ្លីភ្លើៗមួយថ្ងៃៗនឹងសុំលុយម៉ែ500មកម៉ែរឺម៉ែ1000ម
កម៉ែ

ក៖ អ៎ូ!ចឹងហោសអ៊ុំ?

ខ៖ រួចម្តាយចេះតែអោយហើយនឹងចុះអាណិតកូននឹង
មានកូនឆ្កួតមួយប្រុសនឹងអាយុ30ឆ្នាំឆ្កួតភ្លីភ្លើៗ នឹងនៅផ្ទះនឹង

ក៖ ចុះនៅផ្ទះរាល់ថ្ងៃនឹងហោសអ៊ុំ?

ខ៖ មាន5ថ្ងៃចូលផ្ទះម្តង 10ចូលផ្ទះម្តងនឹង

ក៖ ចុះគាត់ទៅណាទៅអ៊ុំចឹង?

ខ៖ វាចេះតែដើរទៅនេះទៅនោះទៅរើសកំប៉ុងទៅណាស់

ក៖ អ៎ូ!ចឹងផងអ៊ុំ?

ខ៖ ហើយជួនណាឃើញគេទុកបាយនៅក្នុងអីមួយចឹងទៅក៏រើសស៊ីចឹងទៅណាស់
ចុះវាមិនដឹងថារបស់ យ៉ាងម៉េចផងបើមនុស្សឆ្កួតទៅហើយនឹង

ក៖ បាទចឹងអ៊ុំ?

ខ៖ បានថាខ្ញុំអើយហូរទឹកភ្នែកហើយនិយាយទៅអាណិតកូននឹង
ថ្នាំនឹងចង់ទិញថ្នាំប្រសៃប្រសាទនឹង ក៏គ្មានលុយទិញអោយដែរនឹង

ក៖ ចឹងចុះធ្វើយ៉ាងម៉េចទៅចឹងអ៊ុំ?

ខ៖ មិនដឹងថាធ្វើយ៉ាងម៉េចទេបើគ្មានទាំងលុយទិញថ្នាំអីអោយផឹកផងនឹង

ក៖ ចុះពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយចិត្តដែរអ៊ុំ?

ខ៖ ទេរាល់ថ្ងៃនឹងគ្មានពេលដែរសប្បាយទេនឹង
បើថាមានប្រាក់ខែអីគេអោយយើងចាយស៊ីនឹងយើង សប្បាយហើយនឹង
រាល់ថ្ងៃនឹងសប្បាយអីសប្បាយតែទៅរកអូសទៅបានមួយបាច់ចឹងទៅ3ពាន់អីចឹងទៅ
ណាស់

កៈ ចុះចឹងយ៉ាប់ដែរ?

ខៈ ចេះតែទៅចឹងទៅរួចរាល់ថ្ងៃនឹងវាឡើងឈាមយើងទៀតនឹង
ដើរទៅជូនកាលងងឹតមុខទៅវា ធ្មេចបើកៗៗនឹង

កៈ បាទចឹងអ៊ុំបាទ?

ខៈ វាមានជំងឺយើងនឹង

កៈ ចុះអ៊ុំធ្លាប់មានក្តីស្រម៉ៃពីនៅក្មេងទេថាអ៊ុំធំឡើងចង់ធ្វើអីគេចឹងហាសអ៊ុំ?

ខៈ ក្តីស្រម៉ៃនឹងជំនាន់ក្តីស្រម៉ៃនឹងខ្ញុំចេះទេនឹង
អញ់ស្តាយខ្លួនណាស់បើអោយទៅច្រៀងអីដូចសូសាវឿន ត្រូវបានឡានជិះបាត់

កៈ អូម៉េចអ៊ុំមិនទៅ?

ខៈ នេះខ្ញុំស្រម៉ៃចឹងតើ!

កៈ ចឹងទេហោសអ៊ុំ?

ខៈ
នឹងហើយខ្ញុំប្រាថ្នាចេះតែជាតិក្រោយនឹងអោយទៅប្រលងចំរៀងនឹងគេអោយចេះដូចសូសាវឿន ចឹងហាស

កៈ អ៊ូ!បាទនឹងហើយ?

ខៈ ខ្ញុំស្រម៉ៃចឹងៗទៅនឹង

កៈ
ចុះបើសិនជាចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ ផ្តែផ្តាំថាចៅហាសគ្រឿងញៀននឹងជីដូននឹងអត់ចូលចិត្តទេ
វាជាប់គុកជាច្រវ៉ាក់ទៅវាអស់ស្រែ អស់ចំការនឹង

កៈ បាទអ៊ុំបាទត្រូវ?

ខ៖
ហើយវានៅគ្រឿងញៀននឹងផឹកស៊ីទៅស្រួលមួយជីវិតនឹងគឺនៅក្នុងគុកនឹងតែម្ដងនឹងងងឹតតែម្ដងនឹង

ក៖ បាទត្រូវនឹងមែនអ៊ុំ?

ខ៖ ចៅឯងមិនអោយមានកើតរឿងគ្រឿងញៀនទេនឹង ចៅឯងរកស៊ីទៅនឹង

ក៖ បានប៉ុណ្ណាយកប៉ុនណុងទៅណាអ៊ុំ?

ខ៖ ធ្វើសំណង់អីទៅបានមួយចាន់ស៊ីមួយចានទៅ
បានមួយគោមនឹងស៊ីមួយគោទៅណាស់រួចទៅចិញ្ចឹម មាន់ ចិញ្ចឹមទាអីចឹងទៅ

ក៖ អូ៎!បាទចឹងហោសអ៊ុំ?

ខ៖ ចិញ្ចឹមមាន់ ទាអីចឹងទៅណាស់បើថាអោយជីដូនវិញកាន់សិល្ប៍ហើយនឹង
បើនិយាយពីគ្រឿងញៀន វិញជីដូនមិនពេញចិត្តសោះនឹងណាស់

ក៖ នឹងអ៊ុំធ្លាប់ប្រាប់គាត់ដែរណាអ៊ុំ?

ខ៖ ប្រាប់ដែររាល់តែថ្ងៃនឹង ប្រាប់ឡើងជ្រុះបបូរមាត់ទៅហើយនឹង

ក៖ អូ៎!បាទអ៊ុំបាទ?

ខ៖ មិនអោយទេរឿងគ្រឿងញៀននឹងណាស់
និយាយពីគ្រឿងញៀននេះមិនមែនជាអ្វីមួយដែរល្អទេ ណាស់ក្មួយ

ក៖ បាទត្រូវហើយអ៊ុំ
ខ៖ មនុស្សវាចូលគុកចូលច្រវ៉ាក់ទៅវាដូចថា អ្នកខ្លះទៅនៅក្នុងគុកមួយជីវិតក៏មានដែរនឹង

ក៖ បាទអ៊ុំ

ខ៖ វាមិនស្គាល់ម៉ែ ស្គាល់ឪ ស្គាល់ជីដូន ស្គាល់ជីតាទេនឹងណាស់
ចុះបើវាជក់ទៅចឹងញៀនទៅជីដូន មិនចូលចិត្តនឹង

ក៖ បាទពិតត្រូវណាស់អ៊ុំ

ខ៖ មិនចូលចិត្តទេរឿងចឹងៗអីនឹង

កៈ មានអីផ្សេងទៀតទេ?

ខៈ អត់អោយប៉ះពាល់ទេរឿងចឹងៗនឹង

កៈ បាទនឹងហើយអ៊ុំ

ខៈ ផ្ដែផ្ដាំដូចចេះដូចថាកូនចៅអើយធ្វើល្អទៅនឹងគង់តែទេវតាព្រុះយើងទេនឹង

កៈ បាទអ៊ុំនឹងត្រូវ

ខៈ បានមួយចានស៊ីមួយចាន
បានមួយគោមនឹងស៊ីមួយគោមទៅកុំប្រព្រឹត្តិអំពើអាក្រក់អីនឹងណាស់ អារឿងគ្រឿងញៀន
រឿងគ្រឿងម៉ាអីនឹងណាស់

កៈ បាទដោយសារតែគ្មានអីចំណេញទេនឹង?

ខៈ នឹងគ្មានអីល្អវិញទេនឹង ផ្ដែផ្ដាំចឹងរាល់តែថ្ងៃនឹងណាស់

កៈ បាទអ៊ុំចឹងមានអីផ្សេងទៀតទេអ៊ុំ?

ខៈ
អោយអីផ្សេងអោយថាបើហែងនឹងចង់មានហែងដឹកមេគោទៅបំបាស់គេយកទៅដឹកទៅ
ណាស់
មួយឆ្នាំនឹងបើបំបាស់អោយគេបាន3ចឹងទៅអោយគេ3យើងយក3ចឹងទៅបានកូនមកបន្ត
ទៀតហើយនឹង បានពង្រីកក្រោលទៀតនឹង

កៈ បាទល្អអ៊ុំ?

ខៈ នឹងហើយវាចឹង

កៈ និយាយរួមទៅផ្ដែផ្ដាំអោយពួកគាត់ចេះរកស៊ីហោសអ៊ុំ?

ខៈ អោយចេះរកស៊ីនឹងហាសអ៊ុំចេះបំបាស់គោនឹង
បំបាស់គោអោយគេដឹកទៅទោះបីលំបាកយ៉ាងម៉េច ក៏ដោយនឹង

កៈ បាទត្រូវទាល់តែតស៊ូណអ៊ុំ?

ខ៖ នឹងហើយរឿងនឹងចឹងបើចៅឯងអត់ត្រីស៊ីទៅយកម្ចងទៅបង់ទៅ
ទៅវាយតាមចឹងទៅកុំយកទូកគេ
ណាស់យកទូកគេគេរវល់តែរកស៊ីដែរយើងចសុខចិត្តទឹកត្រឹមកនឹងទៅដាក់ទៅណាស់
បានប៉ុន្មានយកប៉ុណ្ណឹងមកស៊ីទៅណាស់

ក៖ នៅណាអ៊ុំនៅបឹងខាងក្រោយនឹងហោសអ៊ុំ?

ខ៖ នៅបឹងខាងក្រោយនឹងប្រដៅតែចឹងអត់មានប្រដៅអីទេនឹង
និយាយរួមនឹងប្រដៅតែពាក្យល្អតែម្តង នឹងណាស់

ក៖ បាទអ៊ុំបាទ

ខ៖ ហើយកុំវៃតតប់គេ ហើយកុំជេរគេ

ក៖ កុំអោយឈ្លោះគ្នាណាអ៊ុំ?

ខ៖ ហើយកុំអោយឈ្លោះគ្នានឹងអោយសុខសាន្តរហូតនឹងតរៀងទៅចៅអើយ

ក៖ នឹងអ្វីៗដែរអ៊ុំប្រដៅទៅកូនចៅរាល់ថ្ងៃនឹង?

ខ៖ នឹងហើយប្រដៅរាល់ថ្ងៃនឹងណាស់

ក៖ ហើយនឹងអ្វីដែរអ៊ុំផ្តែផ្តាំនឹងប្រដៅអោយពួកគាត់ធ្វើចឹងណាអ៊ុំ?

ខ៖ នឹងហើយផ្តែផ្តាំតែប៉ុណ្ណឹង

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានពិភាក្សាជាមួយខ្ញុំ
ហើយនឹងផ្តល់ជាប្រវត្តិមកដល់ខ្ញុំអីចឹង
ហាសអ៊ុំដើម្បីខ្ញុំងាចរក្សាពីប្រវត្តិរបស់អ៊ុំទុកទៅក្នុងវេបសាយរបស់សាលា
ហើយដើម្បីជួយតំកល់ទុកអោយអ៊ុំដែរចឹងហាសអ៊ុំ បាទចឹងអរគុណច្រើនអ៊ុំ៕៕៕